# រឿង មហាចោរនៅទល់ដែន

**ភាគទី៦៤** (ក្បួនការពារឯកពជ្យ)

ក្រោយពីពេលដែលនាយកត និងនាយឡំបានរួចពីអណ្តូងមរណភាពមក ជនទាំងពីរបាន ត្រឡប់ទៅកាន់បន្ទាយវិញ។ ថ្វីត្បិតតែរឿងធ្លាក់អណ្តូងនេះ កន្លងទៅបានមួយឆ្នាំមកហើយ តែជន ទាំងពីរនៅនឹកឃើញរឿងនេះហាក់ថ្មីជានិច្ច។ ហេតុនេះហើយបានជាក្នុងឱកាសបុណ្យរបស់ព្រះ កម្ពុតនេះ ជនទាំងពីរប្រុងស្មារតីជាងគេព្រោះអានឹងរឿងអណ្តូងចង្រៃ ដែលគេចេញសឹងពុំរួចនោះ លុះដល់កន្លែងមួយឆ្ងាយពីមនុស្សបន្តិច មហាកាលចាប់ស្មាមិត្តទាំងប្អូននិយាយខ្សឹបៗថា:

រកលោកគ្រូមិនឃើញទេ។

អារុណសើចរួចថា:

ខ្លាចក្រែងគាត់ក្លែងខ្លួនជាអ្នកស្រុកដូចយើងទេដឹង?

វីរៈកាត់ភ្លាម:

រួចមិត្តទាំងប្រាំ ដាក់គូថអង្គុយលើស្មៅដោយអស់សង្ឃឹមថា នឹងរកមានន្ទឱ្យឃើញ។

មហាកាលអង្គុយកណ្តាលមិត្ត ទាំងប្អូនដកដង្ហើមធំពិគ្រោះថា:

គាត់ប្រហែលទៅណាហ្ន៎? ធ្វើម៉េចអោយបានដឹងរឿងនេះឆាប់ៗ? គិតទៅជាងមួយអាទិត្យមក ហើយ ដែលគាត់អញ្ជើញមកបាត់ពីកន្លែង។ ឯងសុំគាត់មកជាមួយផងក៏គាត់មិនឲ្យ។ គិតទៅលោក គ្រូហ៊ានពេកតែម្តង។

វីរៈឆ្លើយថា:

យ៉! បើមិនហ៊ានធ្វើកូនប្រុសម្តេចកើត?

អារុណបញ្ចេញគំនិតថា:

មើល៍! អ្នកណាគ្រាន់បើ ធ្វើយ៉ាងណាឲ្យឃើញលោកគ្រូទាំងយប់នេះ?

មហាកាលងក់ក្បាល:

អឺៗមែន! មើល៍ យើងគិតយ៉ាងណា?

នាយកតលើកដៃភ្ញៀត:

អត្ថបទដោយ៖ មាស សុភាព

យើងដើរទៅរកមើលក្នុងហ្វូងស្រីណាដែលល្អៗ មិនលែងឃើញលោកគ្រូទៅលបមើលគេទេ!

អ្នកទាំងអស់សើចគឹលឡើងៗ មហាកាលដែលសើចដែរ ក៏រាដៃថា:

ធ្លូត! គេនិយាយមែន ឯងគិតពីលេងៗ

នាយឡំ និយាយយ៉ាងស្លូតថា:

ខ្ញុំបាននឹកឃើញហើយ តោង...តោងនាំគ្នាទៅដេកៗ

អារុណសួរភ្លាមថា:

ម៉េចអីចុះវិញ?

ពីព្រោះបើយើងអាល័យតែដើរ លោកគ្រូក៏ដើរកាលណាជួបគ្នា? វាទាល់តែយើងនៅស្ងៀមទើបវាជួបៗ

គេសើចគឹលឡើងៗ មហាកាលទះក្បាលនាយឡំមួយផូង ដែលធ្វើឲ្យនាយកតភ្ញាក់តាំងយំខ្ញង់ៗ

អារុណនិយាយនឹងទួនថា:

ធ្លូត! នៅស្ងៀមៗ គេឮ!

តែវីរៈកាប់មហាកាលផូងៗ ធ្វើអោយទាំងអស់គ្នាស្រឡាំងកាំង រួចឃើញវីរៈផ្ដួលខ្លួនននៀលក្រោកឡើងចាប់ដៃ គេឯងមករួបគ្នាស្ដីថា:

ខ្ញុំនឹកឃើញហើយ!

អារុណ:

យ៉ាងណា? យ៉ាងណា?

ស្ដាប់ខ្ញុំ អ្នកទាំងអស់គ្នា! យើងទៅឡោមព័ទ្ធចាប់និលពេជ្រឈ្លេចសួរវា ទើបដឹងច្បាស់ពីព្រោះនិលពេជ្រវាជាសេនារបស់...!

អ្នកទាំងអស់គ្នាញញឹមញញែម ទះស្មាវីរៈដោយសរសើរគំនិតនេះក្រៃពេកៗ

នាយកតឡើងក្អេងឡើងដែរ:

មែន! ខ្ញុំឃើញវានៅដេកជិតជង្រុកៗ វាប្រហែលមានស្រីផងក៏មិនដឹង!

អត្ថបទដោយ៖ មាស សុភាព

មហាកាលត្រេកអរក្រៃលែង បន្ទរថា:

មែនហើយ! មែនហើយ! កនយើងៗ ទៅឡោមព័ទ្ធចាប់វាឲ្យបាន! ហ៊ឺស! នឹកឃើញអាចង្រៃហ្នឹងឡើងចង់តែស៊ីសាច់ហុតឈាមវាទាំងស្រស់ៗ ទៅកនយើងលបៗទៅ។

នាយអារុណទាញដៃសហការីថយក្រោយខ្សឹបៗថា:

ប្រយ័ត្ន! វាមានទាហានច្រើនណាស់ណ៎ា!

មហាកាលបញ្ជាក់ថា:

យ៉! កុំខ្លាចយប់ថ្ងៃបុណ្យយ៉ាងនេះ អាសត្វនោះវាធ្វេសខ្លួនហើយ ក្រោយពីពេលដែលខ្សឹបខ្សៀវគ្នាអស់ពេលយ៉ាងយូរ ជនទាំងប្រាំនាក់ក៏ដើរលបៗទៅជិតផ្ទះមួយដែលនៅដាច់ឆ្ងាយពីគេៗ

មហាកាលគ្រាន់តែបញ្ជាក់ឡើងវិញ:

កតឯងប្រាកដជាវាដេកនៅផ្ទះនោះមែនឬ?

ខ្ញុំតាមជាប់នឹងភ្នែកៗ ប្រាកដជាវាដេកនៅក្នុងផ្ទះហើយៗ

អារុណញាក់ស្មាដើរទៅមុខឥតរួញរា ដោយពោលពាក្យថា:

ទៅ! ចាប់ធ្វើការឡើង កុំបង្អង់ឲ្យយូរៗ

វីរៈចាប់ស្មាអារុណ:

ធ្វើយ៉ាងណា? ចូលតាមណា? ធ្វើម៉េច?

មហាកាលនិយាយឡើងថា:

អញ! ទុកឲ្យអញ អញចង់សងសឹកនឹងវា! អញរកតែមុខវាឲ្យឃើញនេះឯងៗ ទុកឲ្យអញសម្លាប់វា!

វីរៈសួរទៀតថា:

ចុះបើវាសម្លាប់កាលឯងវិញ តើធ្វើយ៉ាងណា?

**(សូមរង់ចាំតាមដានភាគទី៦៩ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព